ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀងព្យួរកិច្ចសន្យាការងារ

កិច្ចព្រមព្រៀងព្យួរកិច្ចសន្យាការងារនេះ ត្រូវបានធ្វើឡើងនៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០ រវាង

លោក **ហែម សក្កុណា** កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ០១០៩៣៧៤០៥ ដែលមានតួនាទី **នាយកគ្រប់គ្រងទូទៅ** និងជាតំណាងភាគីនិយោជក នៃក្រុមហ៊ុន **អិល&អិម បាសាក់រីវើរ ខូ អិលធីឌី** ដែលមានអាសយដ្ឋានស្ថិតនៅ **អាគារលេខ អិន២ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ** ធ្វើជាមួយនិង ៖

- លោកស្រី **អ៊ុំ សៅឌីណា** កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ១៥០២៧៧៩១៥ ដែលមានតួនាទីជាជំនួយការប្រធានផ្នែកគ្រប់គ្រងភោជនីយដ្ឋាន និងជាតំណាងភាគីនិយោជិកនៃក្រុមហ៊ុនខាងលើ។
- លោកស្រី **សួន ណារ៉ុន** កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ០១១១១៣៣៤៣ ដែលមានតួនាទីជាមេចុងភៅអាហារអឺរ៉ុប និងជាតំណាងភាគីនិយោជិកនៃក្រុមហ៊ុនខាងលើ។

ភាគីទាំងបីបានធ្វើការព្រមព្រៀងគ្នាដូចខាងក្រោម៖

០១- រយៈពេលនៃការព្យួរកិច្ចសន្យាការងារ៖

ការព្យួរកិច្ចសន្យាការងារ ចាប់ពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ ដល់ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ មូលហេតុដោយសារក្រុមហ៊ុនបានទទួលរងនូវផលប៉ះពាល់យ៉ាងអវិជ្ជមានលើផ្នែកហិរញ្ញវត្ថុ ដែលបង្កដោយវីរុស កូវីដ១៩។

០២- ប្រាក់ឧបត្ថម្ភកំឡុងពេលព្យួរកិច្ចសន្យាការងារ៖

ភាគីនិយោជក មិនមានផ្តល់ជាប្រាក់ឧបត្ថម្ភអ្វីឡើយ កំឡុងពេលព្យួរកិច្ចសន្យាការងារនេះ។

ភាគីនិយោជិក មិនទាមទារប្រាក់ឧបត្ថម្ភអ្វីឡើយ ពីនិយោជកក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារនេះ។

០៣- កាលបរិច្ឆេទចូលបម្រើការងារវិញ៖

បុគ្គលិកនិយោជិកទាំងអស់ត្រូវត្រឡប់ចូលមកបម្រើការងារវិញ បន្ទាប់ពីរយៈពេលព្យួរកិច្ចសន្យាការងារនេះត្រូវបានបញ្ចប់។

កិច្ចសន្យានេះត្រូវបានធ្វើឡើងជាពីរ(០២)ច្បាប់និងមានតម្លៃស្មើគ្នាចំពោះមុខច្បាប់ដែលសម្រាប់ភាគីនីមួយៗទុកម្នាក់មួយ(០១)ច្បាប់។

ភាគីទាំងពីរបានអាន ព្រមព្រៀងគ្នា និងបានផ្តិតមេដៃ ដើម្បីជាសាក្ខីភាព៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០

**តំណាងភាគីនិយោជិត**

**លោកស្រី អ៊ុំ សៅឌីណា** **លោកស្រី សួន ណារ៉ុន**

**តំណាងភាគីនិយោជក**

**លោក ហែម សក្កុណា**